# សេចក្ដីថ្លែងការណ៍

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អនុមោទនាអំពីកំណែទំរង់ដីធ្លីរបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា

Website: www.hoksavann.org

ថ្ងៃទី២៨ តុលា ២០០៤

សូមអនុមោទនាត្រេកអរនូវផែនការដកហូតដីធ្លីដែលកាន់កាប់ខុសច្បាប់របស់មន្ត្រីរដ្ឋាភិបាលមានអំណាចនិងអ្នកជំនួញមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ មកប្រគល់ឲ្យកសិករក្រីក្រខ្វះដីធ្លី ឬគ្មានដីធ្លីធ្វើស្រែចំការ ដែលប្រមុខដឹកនាំរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា បានថ្លែងក្នុងឱកាសបើកពិធីវេទិកាដីធ្លីជាតិ នៅវិមានរដ្ឋាភិបាលនាថ្ងៃច័ន្ទ១៨តុលា២០០៤កន្លងទៅនេះ ។

អាត្មាបានថ្លែងការណ៍ជាញឹកញាប់អំពីបញ្ហាដីធ្លីនេះ ដោយទុកបញ្ហានេះជាអាទិភាព ដែលអាត្មាចាប់អារម្មណ៍យ៉ាងខ្លាំង ដោយនឹកអាណិតអាសូរចំពោះប្រជាពលរដ្ឋខ្មែរក្រីក្រ ដែលត្រូវដោះស្រាយជាបន្ទាន់ ព្រោះប្រជាពលរដ្ឋខ្មែរជាកសិករមានជាង៨០% ហើយភាពក្រីក្រនេះមានមូលហេតុមកអំពីកង្វះដីស្រែចំការធ្វើមួយភាគដែរ ។ បន្ទាប់ពីរបបខ្មែរក្រហមត្រូវរលំឆ្នាំ១៩៧៩ ដីស្រែចំការទាំងរបស់រដ្ឋទាំងរបស់ឯកជនពីជំនាន់មុននៅទំនេរ ព្រោះប្រជាពលរដ្ឋខ្មែរត្រូវស្លាប់និងឃ្លាតចាកពីភូមិករ បាត់បង់ប្លង់ដី ឆ្លៀតឱកាសនោះ អ្នកមានអំណាចបានវាតយកដីទាំងនោះ ហើយទៅសេពគប់ជាមួយអាជ្ញាធរពុករលួយ ធ្វើប្លង់ដាក់ថាខ្លួនជាម្ចាស់ដី ។ ការរំលោភមួយបែបទៀត មានឈ្មួញទុច្ចរិតមួយចំនួនបានទៅបញ្ចុះបញ្ចូលប្រជាពលរដ្ឋក្រីក្រដែលមានដីបន្តិចបន្តួច ឲ្យលក់ដីឲ្យខ្លួនដោយតម្លៃយ៉ាងថោក ដើម្បីខ្លួនទុកលក់យកតម្លៃយ៉ាងថ្លៃ ។ ដីដែលអ្នកមានអំណាចនិងឈ្មួញទុច្ចរិតរំលោភយក ត្រូវទុកចោលទំនេរគ្មានធ្វើអភិវឌ្ឍន៍អ្វីឡើយ ។

ការហូតយកដីពីអ្នកមានអំណាចនិងឈ្មួញទុច្ចរិត មកប្រគល់ឲ្យកសិករវិញនេះ ជាអំពើយុត្តិធម៌ណាស់ ដែលត្រូវអនុវត្តជាបន្ទាន់ ។ សូមគាំទ្រចំពោះផែនការណា ដែលរាជរដ្ឋាភិបាលធ្វើត្រូវ ។ សូមសង្ឃឹមថាពាក្យសន្យារបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាលដែលថា បើដោះស្រាយរឿងការរំលោភយកដីធ្លីរបស់រដ្ឋនិងរបស់ប្រជាពលរដ្ឋ ពីសំណាក់អ្នកមានអំណាចមិនបានទេនោះ នឹងចុះចេញពីតំណែង ។ សូមឲ្យការប្ដេជ្ញាចិត្តនេះ ក្លាយជាការអនុវត្តន៍យ៉ាងជាក់ស្ដែង ។ ស្ថានភាពប្រទេសកម្ពុជាពេលនេះ បើគ្មានកំណែទម្រង់ដីធ្លីឲ្យទាន់ពេលវេលាទេ អាចមានបដិវត្តន៍មួយកើតឡើង ពីសំណាក់កសិករក្រីក្រប្រឆាំងនឹងរាជរដ្ឋាភិបាល ។ ជាមួយនេះដែរ បញ្ហាកាប់ឈើខុសច្បាប់ និងបញ្ហាឡូនេសាទក៏ជាបញ្ហាធំដែលត្រូវតែដោះស្រាយជាបន្ទាន់ដែរ ។ ក្រៅពីនេះ បញ្ហារំលោភយកទឹកដីនៃប្រទេសជិតខាង និងបញ្ហាការចូលប្រទេសកម្ពុជាដោយខុសច្បាប់នៃជនជាតិវៀតណាម ជាបញ្ហាសំខាន់ជាអាយុជីវិតជាតិ ក៏ត្រូវតែដោះស្រាយយ៉ាងប្រញាប់ដែរ ។៚